**សន្លឹកព័ត៌មានស្ដីពីថ្នាំវ៉ាក់សាំង**

# ថ្នាំវ៉ាក់សាំងជំងឺហើមសួត
## *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សន្លឹកព័ត៌មានស្ដីពីថ្នាំវ៉ាក់សាំងជាច្រើនមានជាភាសាអេស្ប៉ាញ និងភាសាដទៃទៀត។ សូមចូលទៅwww.immunize.org/vis

## 1 ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

ការចាក់ថ្នាំវ៉ាក់សាំងអាចការពារមនុស្សពេញវ័យ (និងកុមារមួយចំនួន និងយុវជន) ចំពោះ**ជំងឺរលាកសួត**។

ជំងឺរលាកសួត បង្កឡើងដោយបាក់តេរីនូមូកូខល ដែលអាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមការប៉ះពាល់ផ្ទាល់។ ជំងឺនេះអាចបង្កឲ្យកើតជំងឺត្រចៀក ហើយវាក៏អាចបណ្ដាលឲ្យកើតជំងឺធ្ងន់ធ្ងរលើ៖

- សួត (ជំងឺហើមសួត)
- ឈាម (ជំងឺមានបាក់តេរីក្នុងឈាម) និង
- ស្រោមខួរក្បាល និងឆ្អឹងខ្នង (ជំងឺរលាកស្រោមខួរ) ជំងឺរលាកស្រោមខួរ អាចបណ្ដាលឲ្យថ្លង់ និងខូចខួរក្បាល ហើយអាចសម្លាប់ជីវិត។

ជនណាក៏ដោយ អាចកើតជំងឺហើមសួតបង្កឡើងដោយបាក់តេរីនូមូកូខលបាន ប៉ុន្តែ កុមារអាយុក្រោម 2 ឆ្នាំ និងមនុស្សពេញវ័យអាយុលើស 65 ឆ្នាំ និងអ្នកជក់បារី ជាបុគ្គលដែលស្ថិតក្នុងហានិភ័យខ្ពស់បំផុត។

មនុស្សពេញវ័យប្រហែល 18,000 នាក់ ស្លាប់បាត់បង់ជីវិតក្នុងមួយឆ្នាំៗ ដោយសារតែជំងឺរលាកសួតដោយសារបាក់តេរីនូមូកូខល នៅសហរដ្ឋអាមេរិក។

ការព្យាបាលជំងឺហើមសួតដោយប្រើថ្នាំពីនីសីលីន និងថ្នាំដទៃទៀត ធ្លាប់មានប្រសិទ្ធិភាព។ ប៉ុន្តែប្រភេទមួយចំនួននៃជំងឺនេះបានស៊ាំទៅនឹងថ្នាំទាំងនេះ។ ករណីនេះបានធ្វើឲ្យការបង្ការជំងឺនេះតាមរយៈការចាក់ថ្នាំវ៉ាក់សាំងកាន់តែមានសារៈសំខាន់ថែមទៀត។

## 2 ថ្នាំវ៉ាក់សាំងជំងឺហើមសួត (PPSV23)

Pneumococcal polysaccharide vaccine (PPSV23) (ថ្នាំវ៉ាក់សាំងជំងឺហើមសួត) ការពារប្រឆាំងនឹងបាក់តេរីជំងឺហើមសួតចំនួន 23 ប្រភេទ ។ ថ្នាំវ៉ាក់សាំងនេះមិនបង្ការជំងឺហើមសួតដោយសារបាតេរីទាំងអស់ឡើយ។

ថ្នាំវ៉ាក់សាំង PPSV23 ត្រូវបានណែនាំសម្រាប់៖

- មនុស្សពេញវ័យទាំងអស់ដែលមានអាយុ 65 ឆ្នាំ និងលើសនេះ
- អ្នកមានអាយុ 2 ឆ្នាំ ដល់ 64 ឆ្នាំ ដែលមានបញ្ហាសុខភាពរយៈពេលវែង
- អ្នកមានអាយុ 2 ឆ្នាំ ដល់ 64 ឆ្នាំ ដែលមានប្រព័ន្ធស៊ាំចុះខ្សោយ
- មនុស្សពេញវ័យអាយុ 19 ដល់ 64 ឆ្នាំ ដែលជក់បារី ឬមានជំងឺហឺត

មនុស្សភាគច្រើន ត្រូវការថ្នាំវ៉ាក់សាំង PPSV តែមួយដូសទេ។ ដូសទីពីរ ត្រូវបានណែនាំចំពោះក្រុមមនុស្សមានហានិភ័យខ្ពស់ជាក់លាក់។ មនុស្សអាយុ 65 ឆ្នាំ និងលើសនេះ គួរទទួលថ្នាំវ៉ាក់សាំងមួយដូស បើទោះបីជាពួកគេបានទទួលថ្នាំវ៉ាក់សាំងនេះមួយ ឬច្រើនដូស មុនពេលពួកគេឈានដល់វ័យ 65 ឆ្នាំក៏ដោយ។

អ្នកផ្ដល់សេវាថែទាំសុខភាពរបស់លោកអ្នកអាចផ្ដល់ព័ត៌មានបន្ថែមដល់លោកអ្នកអំពីការណែនាំទាំងនេះ។

មនុស្សពេញវ័យសុខភាពល្អភាគច្រើន មានប្រព័ន្ធការពារ ក្នុងរយៈពេល 2 ទៅ 3 សប្ដាហ៍បន្ទាប់ពីទទួលថ្នាំវ៉ាក់សាំង។

## 3 មនុស្សមួយចំនួនមិនគួរទទួលថ្នាក់វ៉ាក់សាំងនេះ។

- អ្នកណាដែលមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរនឹងថ្នាំវ៉ាក់សាំង PPSV មិនគួរចាក់ថ្នាំវ៉ាក់សាំងនេះមួយដូសទៀតទេ។
- នរណាដែលមានបញ្ហាអាឡាក់ស៊ីធ្ងន់ធ្ងរចំពោះធាតុផ្សំណាមួយនៃថ្នាំវ៉ាក់សាំង PPSV មិនគួរទទួលថ្នាំវ៉ាក់សាំងនេះទេ។ សូមប្រាប់អ្នកផ្ដល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកមានបញ្ហាអាឡាក់ស៊ីធ្ងន់ធ្ងរ។
- អ្នកណាដែលឈឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ ពេលកំណត់ត្រូវចាក់ថ្នាំវ៉ាក់សាំងនេះ អាចត្រូវបានគេស្នើឲ្យរង់ចាំរហូតទាល់តែពួកគេជាសះស្បើយសិន មុនពេលទទួលថ្នាំវ៉ាក់សាំង។ ជាធម្មតា អ្នកដែលមានជំងឺស្រាលអាចចាក់ថ្នាំវ៉ាក់សាំងបាន។
- កុមារអាយុតិចជាង 2 ឆ្នាំ មិនគួរទទួលថ្នាំវ៉ាក់សាំងនេះទេ។
- ពុំមានភស្តុតាងបង្ហាញថា ថ្នាំវ៉ាក់សាំង PPSV បង្កគ្រោះថ្នាក់ដល់ស្ត្រីមានផ្ទៃពោះ ឬកូនក្នុងផ្ទៃរបស់នាងឡើយ។ ប៉ុន្តែ ជាការប្រុងប្រយ័ត្ន ស្ត្រីដែលត្រូវការថ្នាំវ៉ាក់សាំងនេះ គួរទទួលថ្នាំវ៉ាក់សាំង មុនពេលមានផ្ទៃពោះ ប្រសិនបើអាចធ្វើទៅបាន។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 4 ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

ដូចថ្នាំដទៃទៀតដែរ រាប់ទាំងថ្នាំវ៉ាក់សាំង ឱកាសនៃការទទួលរងផលរំខាន អាចកើតមាន។ ជាធម្មតា ផលរំខានទាំងនេះ មានកម្រិតស្រាល ហើយបាត់ទៅវិញដោយខ្លួនឯង ប៉ុន្តែប្រតិកម្មធ្ងន់ធ្ងរក៏អាចកើតឡើងផងដែរ។

មនុស្សប្រហែលពាក់កណ្ដាល ដែលចាក់ថ្នាំវ៉ាក់សាំង PPSV មានផលរំខានស្រាល ដូចជា ស្នាមក្រហម ឬការឈឺចុកចាប់ នៅត្រង់កន្លែងចាក់ថ្នាំវ៉ាក់សាំង ដែលបញ្ហាទាំងនេះបាត់ទៅវិញក្នុងរយៈពេលប្រហែលពីរថ្ងៃ។

មនុស្សតិចជាងម្នាក់ ក្នុងចំណោម 100 នាក់ កើតជំងឺគ្រុនក្ដៅ ឈឺសាច់ដុំ ឬមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ នៅត្រង់កន្លែងចាក់ថ្នាំវ៉ាក់សាំង។

**បញ្ហាដែលអាចកើតឡើង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងណាក៏ដោយ៖**

- ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្រមួយ ដែលរួមបញ្ចូលទាំងការចាក់ថ្នាំវ៉ាក់សាំង។ ការអង្គុយ ឬដេកប្រហែល 15 នាទីបន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងអាចជួយបង្ការការសន្លប់ និងរបួសដោយសារដួលបាន។ សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្ដូរ ឬឮសំឡេងហឹងក្នុងត្រចៀក។
- មនុស្សមួយចំនួនអាចឈឺចុកចាប់ខ្លាំងត្រង់ស្មា ហើយពិបាកកម្រើកដៃ នៅពេលចាក់ថ្នាំវ៉ាក់សាំង។ ករណីនេះកម្រកើតឡើងណាស់។
- ថ្នាំណាក៏ដោយ អាចបង្កប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ប្រតិកម្មអាឡាក់ស៊ីទាំងនេះ ដោយសារតែថ្នាំវ៉ាក់សាំង គឺជាបញ្ហាកម្រ ដែលតាមការប៉ាន់ប្រមាណ មានតិចជាង 1 ក្នុងមួយលានដូស ហើយនឹងកើតឡើង ក្នុងរយៈពេលប៉ុន្មាននាទី ទៅប៉ុន្មានម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្ករបួសធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

សុវត្ថិភាពនៃថ្នាំវ៉ាក់សាំង តែងតែស្ថិតក្រោមការតាមដាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ៖ **www.cdc.gov/vaccinesafety/**

## 5 ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្ដៅខ្លាំង ឬឥរិយាបថខុសធម្មតា។

សញ្ញាបង្ហាញពី**ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ** អាចរួមបញ្ចូលកន្ទួរហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្ដើមកើតឡើងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

ប្រសិនបើលោកអ្នកគិតថា វាគឺជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។

ក្រោយមក ប្រតិកម្មគួររាយការណ៍ទៅ Vaccine Adverse Event Reporting System (VAERS) (ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំ)។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈវិបសាយ VAERS នៅ **www.vaers.hhs.gov**ឬហៅទូរស័ព្ទទៅលេខ **1-800-822-7967**។

*VAERS មិនផ្ដល់យោបល់វេជ្ជសាស្ត្រទេ។*

## 6 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នក។ គាត់អាចផ្ដល់ឯកសារក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង ឬប្រាប់ប្រភពព័ត៌មានផ្សេងដល់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬទៅមូលដ្ឋានរបស់លោកអ្នក។
- សូមទាក់ទង Centers for Disease Control and Prevention (CDC) (មជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺ)៖
  - ទូរស័ព្ទមកលេខ **1-800-232-4636** (**1-800-CDC-INFO**) ឬ
  - ចូលទៅវេបសាយ CDC នៅ **www.cdc.gov/vaccines**

Vaccine Information Statement
PPSV Vaccine

4/24/2015

Khmer

Office Use Only

Translation provided by the Immunization Action Coalition